  - នៅពេលយើងនិយាយអំពី**ប្រព័ន្ធផ្តេតហ្វម**របស់យើង ជាទូទៅយើងសំដៅលើបណ្តាញ ឬមធ្យោបាយដែលអ្នកបានប្រើប្រាស់ដើម្បីប្រាស្រ័យទាក់ទងជាមួយយើង។ ប្រព័ន្ធផ្តេតហ្វមដែលសំខាន់មួយគឺ៖
    - **វេបសាយ**របស់យើង។
    - អែបកម្មវិធីរបស់យើង នេះរួមបញ្ចូលទាំងកម្មវិធីឧបករណ៍ចល័តដែលអ្នកដំឡើងនៅលើឧបករណ៍របស់អ្នក និងកម្មវិធីដទៃផ្សេងទៀតដែលយើងអាចប្រើប្រាស់នៅក្នុងប្រព័ន្ធផ្តេតហ្វមរបស់យើង។

## 1. តើនរណាជាអ្នកគ្រប់គ្រងទិន្នន័យរបស់អ្នក?

អ្នកគ្រប់គ្រងទិន្នន័យរបស់អ្នកមានដូចជា៖

- ក្រុមហ៊ុន **ITX MERKEN, B.V.** ជាក្រុមហ៊ុនមួយរបស់ Inditex Group, (“ITX MERKEN”)៖

- អាសយដ្ឋានប្រៃសណីយ៍៖ Nieuwezijds Voorburgwal 307, 1012 RM Amsterdam, the Netherlands.
- អាសយដ្ឋានអ៊ីមែលរបស់មន្ត្រីការពារទិន្នន័យ៖ dataprotection@zara.com.

- **ក្រុមហ៊ុន MITRA ADIPERKASA (CAMBODIA) Co., Ltd (ហៅកាត់ថា "ភាគីអ្នកលក់")៖**
  - អាសយដ្ឋានប្រៃសណីយ៍៖ 18/F អគារធនាគារកាណាឌីយ៉ា អគារលេខ 315 មហាវិថីមុនីវង្ស កែងផ្លូវអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
  - អ៊ីមែលរបស់មន្ត្រីការពារទិន្នន័យ៖ digital.product@map.co.id

និយាយមួយបែបទៀត ទាំងក្រុមហ៊ុន ITX MERKEN ទាំងភាគីអ្នកលក់ (ហៅជារួមថា "យើង" "របស់យើង" ឬ "អ្នកគ្រប់គ្រងរួមគ្នា") គឺជា**អ្នកគ្រប់គ្រងរួមគ្នា**នៃទិន្នន័យនេះ។ នេះមានន័យថា យើងទទួលខុសត្រូវសម្រាប់ការដំណើរការ និងការការពារទិន្នន័យរបស់អ្នក។

## 2. ហេតុអ្វីយើងដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក?

អាស្រ័យលើគោលបំណងដែលយើងដំណើរការទិន្នន័យរបស់អ្នកពីពេលមួយទៅពេលមួយ ដូចបានពន្យល់ខាងក្រោម យើងត្រូវការវិភាគទិន្នន័យមួយ ឬទិន្នន័យផ្សេងទៀត ដែលជាទូទៅមានដូចខាងក្រោម **អាស្រ័យទៅលើករណីនីមួយៗ**៖

- **ទិន្នន័យអត្តសញ្ញាណ**របស់អ្នក (ឧទាហរណ៍ ឈ្មោះរបស់អ្នក នាមត្រកូល រូបភាព ភាសា និងប្រទេសដែលអ្នកធ្វើការប្រាស្រ័យទាក់ទងជាមួយយើង ទិន្ន័យទំនាក់ទំនង ។ល។)

- ព័ត៌មាន**សេដ្ឋកិច្ចនិងប្រតិបត្តិការសាច់ប្រាក់** (ឧទាហរណ៍ ការទូទាត់ប្រាក់របស់អ្នក ឬទិន្នន័យប័ណ្ណធនាគារ ព័ត៌មានអំពីការទិញរបស់អ្នក ការបញ្ជាទិញ ការប្រគល់ត្រឡប់វិញ ។ល។)

- ទិន្នន័យការ**ភ្ជាប់អ៊ីនធឺណិត ទីតាំងភូមិសាស្ត្រ និង/ឬការស្វែងរក** (ឧទាហរណ៍ ទិន្នន័យទីតាំង លេខសម្គាល់ឧបករណ៍ ឬ លេខកូដ ID ផ្សព្វផ្សាយពាណិជ្ជកម្ម ។ល។)

- ព័ត៌មាន**ពាណិជ្ជកម្ម** (ឧទាហរណ៍ ប្រសិនបើអ្នកបានចុះឈ្មោះមកកាន់ព្រឹត្តិព័ត៌មានរបស់យើង)

- ព័ត៌មានអំពី**សជាតិ និងចំណង់ចំណូលចិត្ត**របស់អ្នក។

សូមចងចាំថា នៅពេលយើងសុំអ្នកឱ្យបំពេញទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដើម្បីឱ្យអ្នកអាចចូលទៅប្រើមុខងារ ឬសេវាណាមួយរបស់ប្រព័ន្ធផ្លែតហ្វមយើង យើងនឹងដាក់សញ្ញាសម្គាល់ចន្លោះត្រូវបំពេញមួយចំនួនថា *"ចាំបាច់ត្រូវបំពេញ"* ដោយសារនេះគឺជាព័ត៌មានដែលយើងត្រូវការដើម្បីអាចផ្តល់សេវាកម្ម ឬអនុញ្ញាតឱ្យអ្នកចូលទៅប្រើប្រាស់មុខងារដែលពាក់ព័ន្ធនោះ។ សូមគិតពិចារណាថា ប្រសិនបើអ្នកសម្រេចចិត្តមិនផ្តល់ទិន្នន័យនោះមកយើងទេ អ្នកប្រហែលមិនអាចបញ្ចប់ការចុះឈ្មោះរបស់អ្នក ឬប្រហែលមិនអាចទទួលបានសេវាឬមុខងារទាំងនោះឡើយ។

ក្នុងករណីជាក់លាក់ខ្លះ ភាគីទីបីអាចបានផ្តល់ព័ត៌មានរបស់អ្នកដែលមានរក្សាទុក តាមរយៈការប្រើប្រាស់លក្ខណៈពិសេស ឬសេវាកម្មនៅលើផ្លែតហ្វមរបស់យើង ឧទាហរណ៍ ការទិញផលិតផលរបស់យើង និងការ

ប្រើប្រាស់ជម្រើសដែលមានដើម្បីផ្ញើប័ណ្ណរង្វាន់ ឬការដឹកជញ្ជូនការបញ្ជាទិញណាមួយទៅកាន់អាសយដ្ឋានរបស់យើង។ ក្នុងករណីទាំងនេះ យើងគ្រាន់តែប្រមូលនិងវិភាគទិន្នន័យរបស់អ្នកត្រង់ចំណុចណាដែលពាក់ព័ន្ធនឹងលក្ខណៈពិសេសនេះ ឬសេវាកម្ម ដូចមានចែងនៅក្នុងគោលការណ៍នេះតែប៉ុណ្ណោះ។

នៅក្នុងករណីផ្សេងទៀត យើងអាចប្រមូលព័ត៌មានបែបអកម្ម ដោយសារយើងអាចប្រើឧបករណ៍តាមដានដូចជា ខូឃីប្រាវស័រ និងបច្ចេកវិទ្យាស្រដៀងគ្នាផ្សេងទៀតនៅលើប្រព័ន្ធផ្លេតហ្វមរបស់យើង នៅក្នុងការប្រាស្រ័យទាក់ទងដែលយើងផ្ញើទៅកាន់អ្នក។

អាស្រ័យលើរបៀបនៃការប្រាស្រ័យទាក់ទងជាមួយនឹងប្រព័ន្ធផ្លេតហ្វមរបស់យើង ពោលគឺ អាស្រ័យលើសេវាកម្ម ផលិផល ឬមុខងារដែលអ្នកចង់ទទួលបាន នោះយើងនឹងប្រមូលនិងវិភាគទិន្នន័យរបស់អ្នកសម្រាប់គោលបំណងដូចខាងក្រោមៈ

| **គោលបំណង** | **+ ព័ត៌មាន** |
|---|---|
| 1. ដើម្បីធ្វើការគ្រប់គ្រង**ការចុះឈ្មោះរបស់អ្នកនៅលើប្រព័ន្ធផ្លេតហ្វមនេះ** | ប្រសិនបើអ្នកសម្រេចចិត្តក្លាយជាអ្នកប្រើប្រាស់ដែលបានចុះឈ្មោះលើប្រព័ន្ធផ្លេតហ្វមរបស់យើង ក្រុមហ៊ុន ITX MERKEN ត្រូវការប្រមូលនិងវិភាគទិន្នន័យរបស់អ្នក ដើម្បី**កំណត់អត្តសញ្ញាណអ្នកថាជាអ្នកប្រើប្រាស់**ប្រព័ន្ធផ្លេតហ្វមនេះ និង**ផ្ដល់ការអនុញ្ញាតឱ្យអ្នកចូលទៅប្រើប្រាស់**មុខងារ ផលិតផល និងសេវាកម្មនានាដែលមានផ្ដល់ជូនដល់អ្នក ក្នុងនាមជាអ្នកប្រើប្រាស់ដែលបានចុះឈ្មោះរួច។ អ្នកអាចធ្វើការលុបចោលគណនីអ្នកប្រើប្រាស់ដែលបានចុះឈ្មោះរួច ដោយទាក់ទងមកកាន់យើងតាមផ្នែកសេវាអតិថិជន។<br><br>យើងខ្ញុំសូមជម្រាបជូនអ្នកថា ទិន្នន័យដែលយើងប្រមូលពាក់ព័ន្ធនឹងសកម្មភាពរបស់អ្នក ដែលបានប្រមូលយើងតាមរយៈមធ្យោបាយផ្សេងៗនៃប្រព័ន្ធផ្លេតហ្វមរបស់យើង ហើយដែលរួមបញ្ចូលការទិញរបស់អ្នកជាដើម ត្រូវរក្សាការភ្ជាប់ទៅកាន់គណនីរបស់អ្នក ដើម្បីឱ្យរាល់ព័ត៌មានទាំងអស់នោះ អាចប្រមូលនិងវិភាគរួមបញ្ចូលគ្នា។ |
| 2. សម្រាប់**ការអភិវឌ្ឍ ការដំណើរការ និងការអនុវត្តកិច្ចសន្យាទិញ ឬកិច្ចសន្យាសេវាកម្ម** ដែលអ្នកបានចុះជាមួយយើងនៅលើប្រព័ន្ធផ្លេតហ្វមនេះ។ | គោលបំណងនេះ រួមបញ្ចូលទាំងយើងវិភាគនិងដំណើរការទិន្នន័យរបស់យើង សំខាន់គឺដើម្បីៈ<br><br>▪ **ទាក់ទងទៅកាន់អ្នក**សម្រាប់ការជូនដំណឹងពីការធ្វើបច្ចុប្បន្នភាព ឬការជូនដំណឹងព័ត៌មាន**ពាក់ព័ន្ធនឹងមុខងារ ផលិតផល ឬសេវាកម្មដែលបានចុះកិច្ចសន្យា** រួមបញ្ចូលទាំង **ការស្ទង់មតិអំពីគុណភាព** និងដើម្បីអាចបង្កើនកម្រិតនៃការពេញចិត្តរបស់អតិថិជន ជាមួយនឹងសេវាកម្មដែលបានផ្ដល់ជូន។ |

| គោលបំណង | + ព័ត៌មាន |
| --- | --- |
| | ▪ គ្រប់គ្រងការទូទាត់ថ្លៃផលិតផលដែលអ្នកទិញ ដោយមិនគិតពីនីតិវិធីនៃការទូទាត់ប្រាក់ដែលបានប្រើប្រាស់ឡើយ។<br>ឧទាហរណ៍៖<br>▪ ប្រសិនបើចំពោះការទិញផលិតផលណាមួយតាមរយៈផលិតផលរបស់យើងនៅលើវេបសាយ ឬលើអែបកម្មវិធី អ្នកជ្រើសរើសបើកដំណើរការមុខងារនៃការរក្សាទុកទិន្នន័យទូទាត់ និងអាសយដ្ឋានដឹកជញ្ជូនរបស់យើងសម្រាប់ការទិញនាពេលអនាគត ក្នុងករណីដែលមានផ្តល់ជូនមុខងារនេះ យើងត្រូវការប្រមូលនិងវិភាគទិន្នន័យដែលបានបង្ហាញជូនសម្រាប់ការបើកដំណើរការ និងការអភិវឌ្ឍមុខងារនេះ។ ការផ្តល់ការយល់ព្រមចំពោះការបើកដំណើរការមុខងារនេះ បើកដំណើរការទិន្នន័យទូទាត់បំពេញដោយស្វ័យប្រវត្តិ ដើម្បីបង្ហាញនៅក្នុងការបញ្ជាទិញក្រោយៗទៀត ដើម្បីកុំឱ្យអ្នកចាំបាច់ត្រូវបង្ហាញព័ត៌មានទាំងនោះនៅក្នុងដំណើរការថ្មីណាមួយ ហើយទិន្នន័យទាំងនេះ នឹងត្រូវចាត់ទុកថាមានសុពលភាព និងមានប្រសិទ្ធភាពសម្រាប់ការទិញនៅពេលក្រោយទៀត។ អ្នកអាចផ្លាស់ប្តូរ ឬលុបចោលទិន្នន័យទូទាត់ប្រាក់របស់អ្នកបានគ្រប់ពេល តាមរយៈផ្នែកស្តីពីព័ត៌មានទូទាត់ អាចជាគណនីអ្នកប្រើប្រាស់ដែលបានចុះឈ្មោះជាមួយវេបសាយ ឬផ្នែកគណនីរបស់ខ្ញុំនៅលើអែបកម្មវិធីនេះ។<br>▪ ប្រសិនបើមានផ្តល់ជូន ហើយអ្នកជ្រើសរើសមុខងារនៃអែបកម្មវិធីនេះ ដើម្បីទូទាត់ការបញ្ជាទិញទល់មុខគ្នា យើងត្រូវការប្រមូលនិងវិភាគទិន្នន័យរបស់អ្នកដើម្បីធ្វើការបើកដំណើរការវា ដើម្បីឱ្យអ្នកអាចចាប់ផ្តើមការទិញរបស់អ្នកនៅហាង Brick-and-Mortar Stores ដែលបានបើកដំណើរការសម្រាប់គោលបំណងនេះ។<br>▪ ដើម្បីធ្វើការបើកដំណើរការយន្តការដែលចាំបាច់ដើម្បី**បង្ការ និងចាប់បានការប្រើប្រាស់គ្មានការអនុញ្ញាតនៃប្រព័ន្ធ ផ្លេតហ្វមនេះ** (ឧទាហរណ៍ ក្នុងអំឡុងការទិញ និងដំណើរការប្រគល់មកវិញ ក៏ដូចជា**កំហុសធំៗដែលបានប្រព្រឹត្តប្រឆាំងនឹងអ្នក និង/ឬប្រឆាំងនឹងយើង)**។ ប្រសិនបើយើងចាត់ទុកប្រតិបត្តិការសាច់ប្រាក់នោះថាមានការក្លែងបន្លំ ឬយើងចាប់បានឥរិយាបទមិនប្រក្រតីដែលបង្ហាញពីការប៉ុនប៉ងប្រើប្រាស់ក្លែងបន្លំនៃមុខងារពិសេស ផលិតផល ឬសេវាកម្មរបស់យើង ដំណើរការនេះអាចនាំឱ្យមានផលវិបាកដូចជាការបិទប្រតិបត្តិការសាច់ប្រាក់ ឬការលុបចោលគណនីអ្នកប្រើប្រាស់។ |

| គោលបំណង | + ព័ត៌មាន |
| --- | --- |
| | ▪ ដើម្បីគ្រប់គ្រងការប្តូរប្រាក់ ឬ**ប្រគល់ប្រាក់មកវិញ**ទៅថ្ងៃអនាគត ក្រោយពីអ្នកបានទិញ និងគ្រប់គ្រង**សំណើនៃព័ត៌មានដែលមានផ្តល់ជូនសម្រាប់មាតិកា ការរក្សាទុកផលិតតាមរយៈប្រព័ន្ធផ្តេតហ្វមនេះ** អាស្រ័យលើលទ្ធភាពដែលមានផ្តល់ជូនសម្រាប់ជម្រើសទាំងនោះពីពេលមួយទៅពេលមួយ។<br><br>▪ សម្រាប់គោលបំណងនៃការចេញវិក្កយបត្រ និងដើម្បីផ្តល់ជូនសំបុត្រ និងវិក្កយបត្រនៃការទិញអ្នកបានទិញតាមរយៈប្រព័ន្ធផ្តេតហ្វមនេះ។<br><br>▪ ដើម្បីធានាថា អ្នកអាចប្រើប្រាស់**មុខងារឬសេវាកម្មដទៃទៀត** មានដូចជា ការទិញ បង្កាន់ដៃ ការគ្រប់គ្រង និងការប្រើប្រាស់**ប័ណ្ណរង្វាន់ ឬសក្ខីបត្ររង្វាន់** និងដើម្បីអាចឱ្យអ្នកមានលទ្ធភាពចូលទៅប្រើប្រាស់ **Wi-Fi** ដែលមានផ្តល់ជូនសម្រាប់អតិថិជននៅហាង Brick-and-Mortar Stores។<br><br>▪ ដើម្បីអាចផ្តល់ជូនសេវាកម្មជាក់លាក់តាមរយៈអែបកម្មវិធីនេះ (ដូចជា ប្រព័ន្ធជំនួយក្នុងការស្វែងរកផលិតផល ការកក់បន្ទប់សម្លៀកបំពាក់ ។ល។) ដែលមានផ្តល់ជូននៅហាង Brick-and-Mortar Stores នោះយើងអាចប្រមូលនិងវិភាគទិន្នន័យទីតាំង និងទិន្នន័យទំនាក់ទំនងរបស់អ្នក។ |
| **3.** ដើម្បីបំពេញលក្ខខណ្ឌនៃការស្នើសុំ ឬពាក្យស្នើសុំ ដែលអ្នកបានធ្វើឡើងតាមរយៈបណ្តាញរបស់ផ្នែក**សេវា អតិថិជន** | យើងប្រមូលនិងវិភាគតែទិន្នន័យផ្ទាល់ខ្លួនណាដែលមាន**ការចាំបាច់ខ្លាំងបំផុត** ដើម្បីគ្រប់គ្រង និងដោះស្រាយសំណើសុំ និងពាក្យស្នើសុំរបស់អ្នកតែប៉ុណ្ណោះ។<br><br>ប្រសិនបើអ្នកទាក់ទងមកកាន់យើងតាមទូរសព្ទ នោះការហៅទូរសព្ទអាចត្រូវបានថតទុក ហើយនឹងត្រូវយកមកប្រើប្រាស់តែសម្រាប់គោលបំណងផ្ទៃក្នុងរបស់យើង ឧទាហរណ៍ ដើម្បីប្រើប្រាស់សម្រាប់គោលបំណងនៃការពិនិត្យគុណភាព និងដើម្បីឱ្យយើងអាចឆ្លើយតបទៅនឹងសំណើរបស់អ្នក ហើយនឹងអាចកាត់បន្ថយហានិភ័យស្រដៀងគ្នាចំពោះអតិថិជនដទៃ។ យើងនឹងរក្សាទុកកំណត់ត្រានោះស្របទៅតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។<br><br>ប្រសិនបើមានផ្តល់ជូន ហើយអ្នកជ្រើសរើសប្រើ WhatsApp ជាបណ្តាញដើម្បីប្រាស្រ័យទាក់ទងជាមួយផ្នែកផ្តល់ជំនួយអតិថិជន យើងនឹងចែករំលែកលេខទូរស័ព្ទរបស់អ្នកទៅដល់ក្រុមហ៊ុន WhatsApp Inc. (ក្រុមហ៊ុនមួយដែលមានទីតាំងនៅសហរដ្ឋអាមេរិក) ដើម្បីធ្វើការបញ្ជាក់ថា អ្នកជាអ្នកប្រើប្រាស់សេវាកម្មនេះ។ យើងខ្ញុំសូមណែនាំឱ្យអ្នកធ្វើការត្រួតពិនិត្យការកំណត់សិទ្ធិឯកជន និងអានគោលការណ៍ឯកជនភាពរបស់ WhatsApp ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែម |

| គោលបំណង | + ព័ត៌មាន |
| --- | --- |
| | ទៀតអំពីការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ដែលប្រើប្រាស់សេវារបស់ WhatsApp។<br><br>ប្រសិនបើមាន ហើយអ្នកជ្រើសរើសប្រាស្រ័យទាក់ទងជាមួយផ្នែកផ្តល់ជំនួយអតិថិជនតាមរយៈសេវាឆាតរបស់កម្មវិធីបណ្តាញសង្គម ឬក្រុមហ៊ុនសហការណាមួយផ្សេងទៀត ទិន្នន័យផ្ទាល់ខ្លួនខ្លះរបស់អ្នកដូចជា ឈ្មោះ ឬឈ្មោះអ្នកប្រើប្រាស់ នឹងត្រូវទាញយកពីកម្មវិធីបណ្តាញសង្គមរបស់អ្នក ឬគណនីសហប្រតិបត្តិការ។ សូមចងចាំទុកក្នុងចិត្តថា ទិន្នន័យដែលអ្នកប្រគល់តាមសេវាកម្មនេះ នឹងមានផ្តល់ជូនទៅបណ្តាញសង្គម ឬក្រុមហ៊ុនសហប្រតិបត្តិការរបស់អ្នក និងស្ថិតក្រោមគោលការណ៍ឯកជនភាព ហេតុនេះ យើងសូមណែនាំអ្នកឱ្យធ្វើការពិនិត្យមើលការកំណត់សិទ្ធិឯកជនភាពរបស់អ្នក និងអានគោលការណ៍ឯកជនភាពរបស់បណ្តាញសង្គម ឬក្រុមហ៊ុនសហប្រតិបត្តិការរបស់អ្នក ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែមទៀតអំពីការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក នៅពេលប្រើប្រាស់សេវាកម្មរបស់ពួកគេ។ |
| **4.** សម្រាប់**គោលបំណងធ្វើទីផ្សារ**។ | ក្រុមហ៊ុន ITX MERKEN នឹងប្រមូលនិងវិភាគទិន្នន័យរបស់អ្នកសំខាន់គឺដើម្បីៈ<br><br>▪ កែតម្រូវសេវាកម្មដែលក្រុមហ៊ុន ITX MERKEN ផ្តល់ជូនដល់អ្នក ហើយអាចឱ្យយើងផ្តល់ជាអនុសាសន៍ផ្អែកលើទំនាក់ទំនងរបស់អ្នកជាមួយក្រុមហ៊ុននៅលើប្រព័ន្ធផ្លេតហ្វម និងការវិភាគការប្រើប្រាស់ប្រូហ្វាល់របស់អ្នក (ឧទាហរណ៍ ផ្អែកលើការទិញរបស់អ្នក និងប្រវត្តិនៃស្វែងរករបស់អ្នក)។<br><br>▪ ប្រសិនបើនៅពេលដែលអ្នកចុះឈ្មោះព្រឹត្តិបត្រព័ត៌មានរបស់យើង នោះក្រុមហ៊ុន ITX MERKEN នឹងប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដើម្បី**គ្រប់គ្រងការចុះឈ្មោះទិញរបស់អ្នក** រួមបញ្ចូលទាំងដើម្បី**ផ្ញើព័ត៌មានកែតម្រូវ**អំពីផលិតផល ឬសេវាកម្មរបស់យើងតាមរយៈមធ្យោបាយផ្សេងៗ (ដូចជា អ៊ីមែល ឬសារ SMS)។ ក្រុមហ៊ុន ITX MERKEN ក៏អាចផ្តល់ព័ត៌មាននេះដល់ខាងអ្នកតាមរយៈការជំរុញការជូនដំណឹងក្នុងករណីអ្នកបានបើកដំណើរការមុខងារនេះនៅក្នុងឧបករណ៍របស់អ្នក។<br><br>    ▪ ដូចគ្នានេះដែរ សូមពិចារណាផងដែរថា ការប្រមូលនិងវិភាគទិន្នន័យនេះគឺសំដៅលើ**ការវិភាគទិន្នន័យអ្នកប្រើប្រាស់ ឬប្រូហ្វាល់អតិថិជនរបស់អ្នក**ដើម្បីបញ្ជាក់អំពីចំណង់ចំណូលចិត្តរបស់អ្នក ហេតុនេះបញ្ជាក់ថាតើផលិតផល និងសេវាកម្មមួយណាដែលសក្តិសមបំផុតចំពោះបែបផែនរបស់អ្នក នៅពេលផ្ញើព័ត៌មានទៅកាន់អ្នក។ ឧទាហរណ៍ ផ្អែកលើប្រវត្តិនៃការទិញ និងការស្វែងរករបស់អ្នក (ឧ.ទា. អាស្រ័យលើមុខទំនិញ |

| គោលបំណង | + ព័ត៌មាន |
|---|---|
| | ដែលអ្នកចុចលើ) នោះក្រុមហ៊ុន ITX MERKEN នឹងផ្តល់ការណែនាំជូនដល់អ្នកអំពីផលិតផលដែលអ្នកក្រុមហ៊ុន ITX MERKEN ជឿជាក់ថា អ្នកអាចចាប់អារម្មណ៍ ហើយប្រសិនបើអ្នកគឺជាអ្នកប្រើប្រាស់ដែលបានចុះឈ្មោះរួម នោះយើងនឹងផ្តល់ជូនអ្នកនូវមុខងារ "ទទួលបានរទេះទំនិញមកវិញ"។<br>▪ សូមចងចាំថា **អ្នកអាចឈប់ចុះឈ្មោះចេញពីព្រឹត្តិបត្រព័ត៌មានយើងបានគ្រប់ពេល** ដោយគ្មានគិតថ្លៃអ្វីឡើយ តាមរយៈផ្នែក "ព្រឹត្តិបត្រព័ត៌មាន" នៃប្រព័ន្ធផ្លេតហ្វមនេះ បន្ថែមពីលើការណែនាំដែលយើងបានផ្តល់ជូនអ្នកនៅក្នុងការជូនដំណឹងនីមួយៗ។ ប្រសិនបើអ្នកមិនចង់ទទួលការជំរុញការជូនដំណឹងទេ អ្នកអាចបិទដំណើរការជម្រើសនេះបាននៅក្នុងឧបករណ៍របស់អ្នក។<br>▪ បង្ហាញ**ពាណិជ្ជកម្មនៅលើអ៊ីនធឺណិត**ដល់អ្នក ដែលអ្នកអាចឃើញនៅពេលចូលមើលគេហទំព័រ និងអែបកម្មវិធីផ្សេងៗ ឧទាហរណ៍កម្មវិធីបណ្តាញសង្គមជាដើម។ ពាណិជ្ជកម្មដែលអ្នកឃើញ អាចមានលក្ខណៈចៃដន្យ ប៉ុន្តែក្នុងកាលៈទេសៈខ្លះ ក៏អាចមានពាណិជ្ជកម្មខ្លះដែលពាក់ព័ន្ធនឹងចំណង់ចំណូលចិត្ត ឬប្រវត្តិនៃការទិញ និងការស្វែងរករបស់អ្នកផងដែរ។<br>▪ ប្រសិនបើអ្នកប្រើប្រាស់បណ្តាញសង្គម ក្រុមហ៊ុន ITX MERKEN អាចផ្តល់ជូនដល់ក្រុមហ៊ុននានាដែលខ្លួនសហការជាមួយនូវព័ត៌មានជាក់លាក់ ដើម្បីឱ្យក្រុមហ៊ុនទាំងនោះ អាចបង្ហាញពាណិជ្ជកម្មពីម៉ាកយីហោរបស់យើង ហើយជាទូទៅ ផ្តល់ជូនអ្នកនិងអ្នកប្រើប្រាស់ ដូចជារូបអ្នក នូវការផ្សាយពាណិជ្ជកម្មដែលអាចយកប្រូហ្វាល់របស់អ្នកនៅលើទំព័រព័ត៌មានបណ្តាញសង្គមនោះមកពិចារណា។ ប្រសិនបើអ្នកចង់បានព័ត៌មានអំពីការប្រើប្រាស់ទិន្នន័យរបស់អ្នក និងរបៀបដែលការផ្សាយពាណិជ្ជកម្មនោះដំណើរការនៅលើបណ្តាញសង្គម សូមពិនិត្យមើលគោលការណ៍ឯកជនភាពនៃទំព័របណ្តាញសង្គមដែលមានប្រូហ្វាល់របស់អ្នក។<br>▪ ក្រុមហ៊ុន ITX MERKEN ក៏ប្រើប្រាស់ទិន្នន័យរបស់អ្នកដើម្បី អនុវត្តវិធានការនិងការវិភាគផ្នែកនៅលើពាណិជ្ជកម្មដែលយើងបង្ហាញដល់អ្នកប្រើប្រាស់នៅលើប្រព័ន្ធផ្លេតហ្វមរបស់ក្រុមហ៊ុនសហការរបស់យើងផងដែរ។ ដើម្បីធ្វើបែបនេះ ក្រុមហ៊ុន ITX MERKEN សហការជាមួយភាគីទីបីទាំងអស់នេះ ដើម្បីផ្តល់ជូន |

| **គោលបំណង** | **+ ព័ត៌មាន** |
| --- | --- |
| | បច្ចេកវិទ្យាដែលចាំបាច់ (ឧទាហរណ៍ ខូឃី ភិកសែល SDK ។ល។) ដើម្បីប្រើប្រាស់សេវាកម្មទាំងនេះ។ សូមចងចាំក្នុងចិត្តថា អាចមានការចាំបាច់ដើម្បីផ្តល់ជូនក្រុមហ៊ុនទាំងនោះនូវព័ត៌មានជាក់លាក់ ឬទម្រង់ខ្លះនៃព័ត៌មានកំណត់អត្តសញ្ញាណ (ឧទាហរណ៍ លេខកូដ ID ការផ្សព្វផ្សាយពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងឧបករណ៍ ព័ត៌មានកំណត់អត្តសញ្ញាណពាក់ព័ន្ធនឹងខូឃី ។ល។) ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែមពាក់ព័ន្ធនឹងចំណុចនេះ សូមពិនិត្យមើលគោលការណ៍ស្តីពីខូឃី។ ដូចគ្នានេះដែរ អ្នកអាចកំណត់លេខកូដ ID ផ្សព្វផ្សាយពាណិជ្ជកម្មរបស់អ្នកជាថ្មី ឬបិទដំណើរការពាណិជ្ជកម្មលក្ខណៈ បុគ្គល ដោយធ្វើការកែតម្រូវចំណង់ចំណូលចិត្តរបស់អ្នកនៅក្នុងផ្នែកកំណត់នៃឧបករណ៍របស់អ្នក។<br><br>▪ ភាពសម្បូរបែបនៃទិន្នន័យ៖ នៅពេលក្រុមហ៊ុន ITX MERKEN ប្រមូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកពីប្រភពផ្សេងៗ ក្រុមហ៊ុនអាចរួមបញ្ចូលទិន្នន័យទាំងនោះក្រោមកាលៈទេសៈជាក់លាក់ សម្រាប់គោលបំណងនៃការលើកកម្ពស់ការយល់ដឹងរបស់យើងអំពីតម្រូវការនិងចំណង់ចំណូលចិត្តរបស់អ្នកពាក់ព័ន្ធនឹងផលិតផលនិងសេវាកម្ម (រួមបញ្ចូលទាំងគោលបំណងនៃការវិភាគ ការបង្កើតប្រូហ្វាល់អ្នកប្រើប្រាស់ ការសិក្សាទីផ្សារ ការស្ទង់មតិគុណភាព និងការលើកកម្ពស់ការប្រាស្រ័យទាក់ទងជាមួយអតិថិជនរបស់យើង)។ ឧទាហរណ៍ នេះគឺសំដៅលើវិធីដែលក្រុមហ៊ុន ITX MERKEN អាចរួមបញ្ចូលព័ត៌មានរបស់អ្នក ប្រសិនបើអ្នកមានគណនីមួយដែលបានចុះឈ្មោះ ហើយប្រើប្រាស់អ៊ីមែលតែមួយដែលបានភ្ជាប់ទៅនឹងគណនីរបស់អ្នក អ្នកអាចធ្វើការទិញក្នុងនាមជាភ្ញៀវ ឬសំដៅលើព័ត៌មានដែលប្រមូលចងក្រងដោយស្វ័យប្រវត្តិ (ដូចជា IP និងអាសយដ្ឋាន MAC ឬទិន្នន័យមេតាដេតា) ដែលវាអាចភ្ជាប់ទៅនឹងព័ត៌មានដែលអ្នកបានផ្តល់ជូនយើងដោយផ្ទាល់តាមរយៈសកម្មភាពរបស់អ្នកនៅលើប្រព័ន្ធផ្លេតហ្វម ឬនៅតាមហាងណាមួយរបស់អ្នក (ឧទាហរណ៍ ព័ត៌មានដែលពាក់ព័ន្ធនឹងការទិញរបស់អ្នកមិនថាទិញនៅហាង Brick-and-Mortar Stores ឬតាមអនឡាញ ចំណង់ចំណូលចិត្តរបស់អ្នក ។ល។)។<br><br>▪ ដើម្បីអនុវត្ត**សកម្មភាពផ្សព្វផ្សាយ** (ឧទាហរណ៍ សម្រាប់ការរៀបចំការប្រកួតប្រជែង ឬដើម្បីផ្ញើបញ្ជីទំនិញដែលបានរក្សាទុកទៅកាន់អ៊ីមែលដែលអ្នកបានកំណត់)។ នៅក្នុងការចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្ម អ្នកអនុញ្ញាតឱ្យយើងប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ដែលអ្នកបានចែករំលែកជាមួយយើងផ្អែកលើសកម្មភាពផ្សព្វផ្សាយ |

| គោលបំណង | + ព័ត៌មាន |
|---|---|
| | ពាណិជ្ជកម្ម និងការបញ្ចេញព័ត៌មានតាមរយៈសារព័ត៌មានខុសគ្នា ដូចជាបណ្តាញព័ត៌មានសង្គម ឬប្រព័ន្ធផ្លេតហ្វមនេះតែម្តង ។ នៅក្នុងសកម្មភាពផ្សព្វផ្សាយនីមួយៗដែលអ្នកបានចូលរួម អ្នកនឹងលក្ខខណ្ឌនិងខចែងដែលយើងនឹងផ្តល់ជូនអ្នកនូវព័ត៌មានលម្អិតបន្ថែមអំពីការប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។<br>▪ ដើម្បីធ្វើការផ្សព្វផ្សាយរូបថតឬរូបភាពនៅក្នុងប្រព័ន្ធផ្លេតហ្វម ឬតាមរយៈឆាណែលក្នុងបណ្តាញព័ត៌មានសង្គមដែលអ្នកបានចែករំលែកជាសាធារណៈ ប្រសិនបើអ្នកបានផ្តល់ការយល់ព្រមជាក់ច្បាស់ដល់ក្រុមហ៊ុន ITX MERKEN សម្រាប់គោលបំណងនេះ។ |
| **5. ការវិភាគអំពីលទ្ធភាពអាចប្រើបាន និងគុណភាព** ដើម្បីពង្រឹងសេវាកម្មរបស់យើង | ប្រសិនបើចូលទៅប្រើប្រព័ន្ធផ្លេតហ្វមរបស់យើង នោះក្រុមហ៊ុន ITX MERKEN នឹងជូនដំណឹងដល់អ្នកថា ក្រុមហ៊ុននឹងចាត់ទុកទិន្នន័យស្វែងរករបស់អ្នកសម្រាប់គោលបំណងនៃ**ការវិភាគនិងធ្វើស្ថិតិ** ដូចជាដើម្បីធ្វើការស្វែងយល់ពីលក្ខណៈដែលអ្នកប្រើប្រាស់ប្រាស្រ័យទាក់ទងជាមួយប្រព័ន្ធផ្លេតហ្វមរបស់យើង និងពាក់ព័ន្ធនឹងសកម្មភាពដែលយើងអនុវត្តនៅលើវេបសាយ និងអែបកម្មវិធីដទៃផ្សេងទៀត ដើម្បីឱ្យយើងអាចពង្រឹងសេវាកម្មរបស់យើង។<br>បន្ថែមលើនេះ ក្រុមហ៊ុន ITX MERKEN ក៏អនុវត្តការស្ទង់មតិគុណភាព និងវិធានការផ្សេងៗ ដើម្បីស្វែងយល់ពីកម្រិតនៃការពេញចិត្តរបស់អតិថិជន និងអ្នកប្រើប្រាស់របស់យើង និងកំណត់ពីផ្នែកផ្សេងៗដែលយើងអាចធ្វើការកែលម្អបាន។ |

## 3. តើយើងទទួលបានការអនុញ្ញាតស្របច្បាប់ដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់អ្នកតាមរបៀបណា?

លក្ខខណ្ឌផ្លូវច្បាប់ដែលយើងទទួលបានការអនុញ្ញាតឱ្យប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ក៏អាស្រ័យលើគោលបំណងដែលយើងប្រមូលនិងវិភាគទិន្នន័យទាំងនោះផងដែរ ដូចមានពន្យល់នៅក្នុងតារាងខាងក្រោម៖

| គោលបំណង | សមត្ថភាពផ្លូវច្បាប់ |
|---|---|
| **1. ដើម្បីធ្វើការគ្រប់ការចុះឈ្មោះអ្នកប្រើប្រាស់កម្មវិធីរបស់អ្នក** | ក្រុមហ៊ុន ITX MERKEN ប្រមូលនិងវិភាគទិន្នន័យរបស់អ្នកដោយសារនេះ**គឺជាការចាំបាច់ចំពោះលក្ខខណ្ឌដែលកំណត់លើការប្រើប្រាស់ប្រព័ន្ធផ្លេតហ្វមនេះ**។ ម្យ៉ាងទៀត ដើម្បីឱ្យ |

| | |
|---|---|
| | អ្នកអាចចុះឈ្មោះក្លាយជាអ្នកប្រើប្រាស់ប្រព័ន្ធផ្លែតហ្វមនេះបាន ក្រុមហ៊ុន ITX MERKEN ត្រូវការប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ព្រោះថា បើពុំដូច្នោះទេ ក្រុមហ៊ុននឹងមិនអាចគ្រប់គ្រងការចុះឈ្មោះរបស់អ្នកបានឡើយ។<br><br>យើងចាត់ទុកថា យើងមានផលប្រយោជន៍ស្របច្បាប់ ដើម្បីភ្ជាប់ទៅកាន់គណនីរបស់អ្នកនូវការទិញរបស់អ្នក និងទិន្នន័យដែលប្រមូលបានតាមរយៈបណ្តាញខុសៗនៃប្រព័ន្ធផ្លែតហ្វមនេះពាក់ព័ន្ធនឹងសកម្មភាពរបស់អ្នក។ |
| **2. ការអភិវឌ្ឍ ដំណើរការ និងការចុះកិច្ចសន្យាទិញ ឬកិច្ចសន្យាសេវាកម្ម** | យើងប្រមូលនិងវិភាគទិន្នន័យរបស់អ្នកដោយសារតែដំណើរការរបស់វាមានការចាំបាច់សម្រាប់ឱ្យយើង**ធ្វើការចុះកិច្ចសន្យាទិញ ឬកិច្ចសន្យាសេវាកម្ម**ជាមួយអ្នក។<br><br>ការប្រមូលនិងការវិភាគទិន្នន័យជាក់លាក់ពាក់ព័ន្ធនឹងដំណើរការនៃការទិញ ត្រូវបើកដំណើរការដោយសារតែអ្នកស្នើសុំ ឬអនុញ្ញាតវាដោយស្វ័យប្រវត្តិតាមប្រព័ន្ធនេះតែប៉ុណ្ណោះ ដូចជាករណីនៃការរក្សាទុកទិន្នន័យនៃការទូទាត់ប្រាក់សម្រាប់ការទិញទៅអនាគត ឬការប្រមូលនិងវិភាគទិន្នន័យដែលចាំបាច់ដើម្បីធ្វើការស្កែនវិក្កយបត្រដាក់ប្រាក់តាមរយៈផ្នែក Wallet របស់អែបកម្មវិធី ឬដើម្បីផ្តល់ជូនអ្នកនូវមុខងារ Coming Soon / Back Soon ក្នុងករណីដែលមុខងារទាំងនេះ មានផ្តល់ជូន។ ក្នុងករណីទាំងនេះ ការប្រមូលនិងការវិភាគទិន្នន័យរបស់អ្នក ត្រូវមាន**ការយល់ព្រម**ដោយផ្ទាល់ពីអ្នក។ បន្ថែមលើនេះ យើងប្រមូលនិងវិភាគទិន្នន័យទីតាំងរបស់អ្នក នៅពេលអ្នកផ្តល់ការយល់ព្រមរបស់អ្នក ដើម្បីឱ្យយើងផ្តល់សេវាកម្មជាក់លាក់តាមរយៈអែបកម្មវិធីនេះ នៅពេលចូលទៅកាន់ហាង Brick and Mortar Stores របស់យើង។<br><br>យើងចាត់ទុកថា យើងមានប្រយោជន៍ស្របច្បាប់ក្នុងការអនុវត្តការផ្ទៀងផ្ទាត់ដែលចាំបាច់ដើម្បីចាប់ និងបង្ការការប្រើប្រាស់ក្លែងបន្លំ ឬការឆបោកនៃប្រព័ន្ធផ្លែតហ្វមនេះ ឧទាហរណ៍ នៅពេលអ្នកធ្វើការទិញ ឬប្រគល់ទំនិញត្រឡប់មកវិញ។ យើងយល់ថា ការប្រមូលនិងវិភាគទិន្នន័យទាំងនេះគឺមានលក្ខណៈវិជ្ជមានសម្រាប់គ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់៖ ចំពោះអ្នក វានឹងអនុញ្ញាតឱ្យយើងចាត់វិធានការប្រឆាំងនឹងការការពុំនប៉ងឆបោកលើរូបអ្នក ដែលប្រព្រឹត្តដោយភាគីទីបី។ ចំពោះយើងវិញ វាអនុញ្ញាតឱ្យយើងជៀសវាងការប្រើប្រាស់ប្រព័ន្ធផ្លែតហ្វមនេះដោយគ្មានការអនុញ្ញាត។ ចំពោះអតិថិជន និងសង្គមទាំងមូល វាក៏ឱ្យជួយឱ្យយើងការពារផលប្រយោជន៍របស់ពួកគេ ដោយជានា |

| | |
|---|---|
| | ថា មិនមានការអនុញ្ញាតឱ្យប្រព្រឹត្តសកម្មភាពក្លែងបន្លំ ហើយចាប់បាននៅពេលមានសកម្មភាពនេះប្រព្រឹត្តឡើង។ |
| **3. ផ្នែកសេវាអតិថិជន** | យើងចាត់ទុកថា យើងមានផលប្រយោជន៍ស្របច្បាប់ក្នុងការឆ្លើយតបទៅនឹងសំណើសុំ ឬសំណួរដែលអ្នកបានស្នើសុំឬចោទសួរតាមរយៈបណ្ដាញទំនាក់ទំនងខុសៗគ្នាដែលមានស្រាប់។ យើងយល់ថា ការប្រមូលនិងវិភាគទិន្នន័យទាំងនេះ ក៏មានប្រយោជន៍ដល់អ្នកផងដែរ ក្នុងកម្រិតមួយដែលវាអនុញ្ញាតឱ្យយើងជួយអ្នកឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបនឹងសំណួរដែលបានលើកឡើង។<br><br>ជាពិសេស នៅពេលអ្នកទាក់ទងជាមួយយើង សម្រាប់ការគ្រប់គ្រងគ្រោះថ្នាក់កើតឡើងពាក់ព័ន្ធនឹងការបញ្ជាទិញ ឬផលិតផល/សេវាកម្មដែលទទួលបានតាមរយៈប្រព័ន្ធផ្លែតហ្វមនេះ ការប្រមូលនិងវិភាគទិន្នន័យរបស់អ្នក គឺចាំបាច់ដើម្បី**អនុវត្តកិច្ចសន្យាទិញ**។<br><br>នៅពេលសំណើរបស់អ្នកពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិរបស់អ្នកដែលយើងបានជូនដំណឹងទៅអ្នកដូចខាងក្រោម ឬដើម្បីទាមទារផលិតផលឬសេវាកម្មរបស់យើង នោះយើងទទួលបានការអនុញ្ញាតស្របច្បាប់ដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់អ្នក**សម្រាប់អនុលោមភាពតាមកាតព្វកិច្ចស្របច្បាប់របស់យើង**។ |
| **4. ការធ្វើទីផ្សារ** | ក្រុមហ៊ុន ITX MERKEN ទទួលបានការអនុញ្ញាតស្របច្បាប់ដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់អ្នកសម្រាប់គោលបំណងធ្វើការផ្សព្វផ្សាយទីផ្សារ ដោយមានការយល់ព្រមដែលអ្នកបានផ្ដល់ជូន ឧទាហរណ៍ នៅពេលអ្នកយល់ព្រមទទួលយកព័ត៌មានកែតម្រូវតាមរយៈបណ្ដាញជាច្រើន នៅពេលអនុញ្ញាតការផ្ញើការជំរុញការជូនដំណឹងនៅក្នុងឧបករណ៍របស់អ្នក នៅពេលអ្នកភ្ជាប់វានៅក្នុងការកំណត់ឯកជនភាពលើឧបករណ៍របស់អ្នក នៅពេលអ្នកយល់ព្រមតាមរយៈការកំណត់ខូឃី ឬនៅពេលទទួលយកលក្ខខណ្ឌនិងខចែងផ្លូវច្បាប់ ដើម្បីចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្ម ឬដើម្បីបង្ហោះរូបភាពរបស់អ្នកលើប្រព័ន្ធផ្លែតហ្វម ឬនៅលើឆាណែលរបស់បណ្ដាញសង្គមរបស់យើង។<br><br>ដើម្បីផ្ដល់ជូនសេវាកម្មលក្ខណៈបុគ្គលជូនដល់អ្នក ឬដើម្បីបង្ហាញនូវព័ត៌មានកែតម្រូវ មិនថានៅលើប្រព័ន្ធផ្លែតហ្វមនេះ ឬប្រព័ន្ធផ្លែតហ្វមរបស់ភាគីទីបីទេ ក៏ដូចជាដើម្បីចូលរួមក្នុងភាពសម្បូរបែបនៃទិន្នន័យ នោះក្រុមហ៊ុន ITX MERKEN ចាត់ថាខ្លួនមានផលប្រយោជន៍ស្របច្បាប់ក្នុងការអនុវត្តការកំណត់បុគ្គលិកលក្ខណៈតាមព័ត៌មានដែលខ្លួនមានពាក់ព័ន្ធនឹងអ្នក (ដូចជាប្រវត្តិនៃការស្វែងរក |

| | |
|---|---|
| | ចំណង់ចំណូលចិត្ត ឬការទិញ) និងទិន្នន័យផ្ទាល់ខ្លួនដែលអ្នកបានផ្តល់ជូនយើង ដូចជាកម្រិតអាយុ ឬភាសាជាដើម ដោយសារក្រុមហ៊ុន ITX MERKEN យល់ថា ការប្រមូលនិងវិភាគទិន្នន័យនៃទិន្នន័យទាំងនេះ ក៏មានប្រយោជន៍ដល់អ្នកផងដែរ ដោយសារវាអនុញ្ញាតឱ្យអ្នកជួយកែលម្អបទពិសោធអ្នកប្រើប្រាស់របស់អ្នក និងចូលទៅមើលព័ត៌មានស្របទៅតាមចំណង់ចំណូលចិត្តរបស់អ្នក។ |
| **5. ការវិភាគអំពីលទ្ធភាពអាចប្រើបាន និងគុណភាព** | យើងចាត់ទុកថាក្រុមហ៊ុន ITX MERKEN **មានផលប្រយោជន៍ស្របច្បាប់**ក្នុងការវិភាគលទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធ ផ្លេតហ្វមនេះ និងកម្រិតនៃការពេញចិត្តរបស់អ្នកប្រើប្រាស់ ដោយសារយើងយល់ថា ការប្រមូលនិងវិភាគទិន្នន័យទាំងនេះ ក៏មានប្រយោជន៍ដល់អ្នកផងដែរ ដោយសារគោលបំណងនេះ គឺដើម្បីកែលម្អបទពិសោធអ្នកប្រើប្រាស់ និងផ្តល់នូវសេវាកម្មដែលមានគុណភាពខ្ពស់។ |

## 4. តើយើងនឹងរក្សាទុកទិន្នន័យរបស់អ្នកយូរប៉ុនណា?

**រយៈពេលដែលយើងនឹងរក្សាទុក**ទិន្នន័យរបស់អ្នក អាស្រ័យលើគោលបំណងដែលយើងប្រមូលនិងវិភាគទិន្នន័យនោះ ដូចមានពន្យល់ខាងក្រោមៈ

| គោលបំណង | ពេលវេលាដែលត្រូវរក្សាទុកទិន្នន័យ |
|---|---|
| **1. ដើម្បីធ្វើការគ្រប់គ្រងការចុះឈ្មោះអ្នកប្រើប្រាស់កម្មវិធីរបស់អ្នក** | ITX MERKEN នឹងប្រមូលនិងវិភាគទិន្នន័យរបស់អ្នក ក្នុងអំឡុងពេលដែលអ្នកបន្តធ្វើជាអ្នកប្រើប្រាស់ដែលបានចុះឈ្មោះ (មានន័យថា រហូតទាល់តែអ្នកសម្រេចចិត្តឈប់ចុះឈ្មោះទិញ)។ |
| **2. ការអភិវឌ្ឍ ដំណើរការ និងការចុះកិច្ចសន្យាទិញ ឬកិច្ចសន្យាសេវាកម្ម** | យើងនឹងវិភាគនិងប្រមូលទិន្នន័យរបស់អ្នកសម្រាប់ពេលវេលាដែលចាំបាច់ ដើម្បីគ្រប់គ្រងការទិញផលិតផល ឬសេវាកម្មដែលអ្នកទិញ រួមបញ្ចូលទាំងការប្រគល់មកវិញ បណ្តឹង ឬការទាមទារពាក់ព័ន្ធនឹងការទិញផលិតផល ឬសេវាកម្មដែលពាក់ព័ន្ធ។<br><br>ពេលខ្លះ យើងប្រមូលនិងវិភាគទិន្នន័យតែពេលអ្នកសម្រេចចិត្តប៉ុណ្ណោះ ដូចជាករណីទិន្នន័យទូទាត់ដែលអ្នកបានស្នើសុំមកកាន់យើង ដើម្បីរក្សាទុកដើម្បីធ្វើការទិញនៅថ្ងៃមុខ (ក្នុងករណីដែលដែលមុខងារពិសេសនេះមានផ្តល់ជូន)។ |

| គោលបំណង | ពេលវេលាដែលត្រូវរក្សាទុកទិន្នន័យ |
| --- | --- |
| **3. ផ្នែកជំនួយអតិថិជន** | យើងនឹងប្រមូលនិងវិភាគទិន្នន័យរបស់អ្នកសម្រាប់ពេលវេលាដែលចាំបាច់ ដើម្បីបំពេញតាមសំណើសុំ ឬពាក្យស្នើសុំរបស់អ្នក។ |
| **4. ការធ្វើទីផ្សារ** | ក្រុមហ៊ុន ITX MERKEN នឹងប្រមូលនិងវិភាគទិន្នន័យរបស់អ្នក រហូតទាល់តែឈប់ចុះឈ្មោះទិញ ឬលុបចោលការចុះឈ្មោះទិញរបស់អ្នកទៅកាន់ព្រឹត្តិបត្រព័ត៌មាន។<br><br>ដូចគ្នានេះដែរ យើងនឹងបង្ហាញអ្នកនូវពាណិជ្ជកម្មលក្ខណៈបុគ្គលសម្រាប់អ្នក រហូតដល់អ្នកផ្លាស់ប្តូរឧបករណ៍ កម្មវិធីប្រាវស័រ ឬការកំណត់ខូឃី ដើម្បីឱ្យការអនុញ្ញាតបែបនោះ ត្រូវបានលុបចោល។<br><br>ប្រសិនបើអ្នកចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្ម យើងនឹងរក្សាទុកទិន្នន័យនោះក្នុងរយៈពេលប្រាំមួយ (6) ខែ គិតចាប់ពីចុងបញ្ចប់នៃសកម្មភាពនោះ។ ក្នុងអំឡុងពេលប្រាំមួយ (6) ខែនេះ ប្រសិនបើគ្មានប្រតិបត្តិការសាច់ប្រាក់ថ្មីណាមួយត្រូវបានធ្វើឡើងទេ យើងនឹងរក្សាទុកទិន្នន័យរបស់អ្នកសម្រាប់រយៈពេលដែលបានអនុញ្ញាតដោយច្បាប់និងបទប្បញ្ញត្តិជាធរមាន។ |
| **5. ការវិភាគអំពីលទ្ធភាពអាចប្រើបាន និងគុណភាព** | ក្រុមហ៊ុន ITX MERKEN នឹងប្រមូលនិងវិភាគទិន្នន័យរបស់អ្នកម្តងម្កាលសម្រាប់រយៈពេលដែលយើងបន្តអនុវត្តសកម្មភាពឬការស្ទង់មតិគុណភាពជាក់លាក់ណាមួយ ឬរហូតដល់ក្រុមហ៊ុន ធ្វើអនាមិកទៅលើទិន្នន័យស្វែងរករបស់អ្នក។ |

ពិតមែនតែយើងនឹងប្រមូលនិងវិភាគទិន្នន័យរបស់អ្នកសម្រាប់ពេលវេលាដែលចាំបាច់ដើម្បីសម្រេចគោលបំណងដែលបានលើកឡើងនោះក៏ដោយ យើងនឹងរក្សាទុកទិន្នន័យជាបន្តបន្ទាប់ ដោយរក្សាទុកនិងការពារត្រឹមត្រូវសម្រាប់ពេលវេលាដែលមានការចាំបាច់សម្រាប់ការប្រមូលនិងវិភាគ ស្របទៅតាមបទប្បញ្ញត្តិជាធរមាន ពីពេលមួយទៅពេលមួយ។ នៅពេលដែលសកម្មភាពសក្តានុពលនោះហួសកាលកំណត់ នោះយើងនឹងបន្តធ្វើការលុបចោលទិន្នន័យផ្ទាល់ខ្លួននោះ។

## 5. តើយើងចែករំលែកទិន្នន័យរបស់អ្នកជាមួយភាគីទីបីដែរទេ?

ដើម្បីសម្រេចនូវគោលបំណងដែលមានចែងនៅក្នុងគោលការណ៍នេះ យើងត្រូវផ្តល់ការអនុញ្ញាតឱ្យចូលទៅប្រើទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ជូនដល់**ស្ថាប័នរបស់ក្រុមហ៊ុន Inditex Group** និង**ភាគីទីបី** ដែលផ្តល់ជំនួយដល់យើងនៅក្នុងសេវាកម្មដែលយើងផ្តល់ជូនដល់អ្នក មានដូចជា៖

- ស្ថាប័ន**ហិរញ្ញវត្ថុ**
- អង្គភាព**កំណត់និងបង្ការការក្លែងបន្លំ**
- ក្រុមហ៊ុនផ្តល់សេវា**បច្ចេកវិទ្យា និងវិភាគ**
- ក្រុមហ៊ុនផ្តល់សេវា និងដៃគូផ្តល់សេវាដែលពាក់ព័ន្ធនឹង **ភស្តុភារកម្ម ការដឹកជញ្ជូន និងការប្រគល់ទំនិញ** និង/ឬគ្រឹះស្ថានជាដៃគូរបស់ពួកគេ
- ក្រុមហ៊ុនផ្តល់សេវាដែលពាក់ព័ន្ធនឹង**ផ្នែកជំនួយអតិថិជន**
- ក្រុមហ៊ុនផ្តល់សេវា និងអ្នកសហការដែលពាក់ព័ន្ធនឹង**ការធ្វើទីផ្សារ និងផ្សព្វផ្សាយជាសាធារណៈ** ដូចជាភ្នាក់ងារផ្សាយពាណិជ្ជកម្ម ដៃគូផ្សាយពាណិជ្ជកម្ម ឬបណ្តាញព័ត៌មានសង្គម ដែលក្នុងករណីជាក់លាក់ខ្លះអាចដើរតួជាអ្នកគ្រប់គ្រងរួមគ្នា។

សម្រាប់គោលបំណងនៃភាពងាយស្រួលខាងសេវាកម្ម ក្រុមហ៊ុនផ្តល់សេវាទាំងនេះមានទីតាំងនៅក្នុងដែនដីក្រៅពីតំបន់សេដ្ឋកិច្ចអឺរ៉ុប ដែលពុំផ្តល់កម្រិតនៃការការពារទិន្នន័យឱ្យបានដូចគ្នានឹងសហភាពអឺរ៉ុប។ ក្នុងករណីទាំងនោះ ក្រុមហ៊ុន ITX MERKEN នឹងផ្តល់ផ្ទេរទិន្នន័យរបស់អ្នកដោយមាន**ការការពារគ្រប់គ្រាន់ ហើយតែងរក្សាទុកទិន្នន័យរបស់អ្នកឱ្យមានសុវត្ថិភាពជានិច្ច** ដោយប្រើប្រាស់ឧបករណ៍ផ្ទេរទិន្នន័យអន្តរជាតិដែលងាយស្រួលបំផុត ឧទាហរណ៍ មាត្រាកិច្ចសន្យាស្តង់ដា និងវិធានការបំពេញបន្ថែមដែលពាក់ព័ន្ធណាមួយ។ អ្នកអាចប្រឹក្សាយោបល់ខ្លឹមសារនៃមាត្រាកិច្ចសន្យាស្តង់ដា តាមរយៈតំណភ្ជាប់នេះ៖ https://ec.europa.eu/info/law/law-topic/data-protection/data-transfers-outside-eu/model-contracts-transfer-personal-data-third-countries_en

បន្ថែមលើនេះ ក្រុមហ៊ុន ITX MERKEN ជូនដំណឹងដល់អ្នកថា យើងត្រូវការចែករំលែកទិន្នន័យរបស់អ្នកជាមួយក្រុមហ៊ុនមេរបស់យើង គឺក្រុមហ៊ុន **Industria de Diseño Textil, S.A. (Inditex, S.A.)**, ក្រុមហ៊ុនហូលឌីង Inditex Group ដែលមានទីតាំងនៅប្រទេសអេស្ប៉ាញ ដើម្បីអនុលោមភាពជាមួយកាតព្វកិច្ចរបស់ក្រុមហ៊ុនមេ។

ក្នុងករណីដែលក្រុមហ៊ុន ITX MERKEN លក់ ឬ ផ្ទេរអាជីវកម្ម ឬទ្រព្យសកម្មទាំងអស់ ឬក្នុងចំណែកខ្លះទៅកាន់ក្រុមហ៊ុនផ្សេងទៀតនៅក្នុងឬក្រៅក្រុមហ៊ុន Inditex Group ឬមានដំណើរការអាជីវកម្មណាមួយទៀតដោយអនុវត្តជាលទ្ធផលនៃការរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុនឡើងវិញ នោះក្រុមហ៊ុន ITX MERKEN អាចបញ្ចេញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកទៅកាន់អ្នកទទួលអាជីវកម្ម ឬទ្រព្យសកម្មទៅអនាគតនោះ។ ប្រសិនបើការលក់ ឬការផ្ទេរនោះកើតឡើងមែន នោះក្រុមហ៊ុន ITX MERKEN នឹងប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងដែលសមហេតុផលដើម្បីណែនាំអ្នកទទួលការផ្ទេរនោះឱ្យប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដែលអ្នកបានផ្តល់មកយើងក្នុងលក្ខណៈដែលស្របតាមគោលការណ៍របស់យើង។ ក្នុងករណីនេះ ក្រុមហ៊ុន ITX MERKEN ចាត់ទុកថាខ្លួនមានផលប្រយោជន៍ស្របច្បាប់ ដែលមាននៅក្នុងការរៀបចំរចនាសម្ព័ន្ធក្រុមហ៊ុនរបស់យើងឡើងវិញនោះ។

បន្ថែមលើនេះ ប្រសិនបើអ្នកជ្រើសរើសផ្លេតហ្វមនៅក្នុងផ្សារខុសវិញ (ឧ.ទា. តាមរយៈការបង្កើតគណនីអ្នកប្រើប្រាស់ដែលបានចុះឈ្មោះនៅក្នុងទីផ្សារខុសៗគ្នាដោយប្រើអាសយដ្ឋានអ៊ីមែលតែមួយ) នោះក្រុមហ៊ុន ITX MERKEN អាចត្រូវការបញ្ចេញព័ត៌មាន ឬផ្ទេរព័ត៌មានដែលបានភ្ជាប់ទៅកាន់គណនីរបស់អ្នក ឬសកម្មភាពរបស់អ្នក ទៅកាន់ក្រុមហ៊ុនដែលមានម៉ាកយីហោដំណើរការនៅក្នុងនៅទីផ្សារទាំងនោះ ក្នុងកម្រិតដែលមាន

ការពាក់ព័ន្ធដោយផ្ទាល់នឹងសមិទ្ធផលនៃគោលបំណងណាមួយដែលមានចែងនៅក្នុងផ្នែកទី 2។ ក្រុមហ៊ុន ITX MERKEN ចាត់ទុកថា នេះគឺជាការចាំបាច់ស្របតាមផលប្រយោជន៍ និងចំណង់ចំណូលចិត្តទៅវិញទៅមក។

បន្ថែមលើនេះ ដើម្បីសម្រេចគោលបំណងដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ដំណើរការ និងការចុះកិច្ចសន្យាទិញ ឬកិច្ចសន្យាសេវាកម្ម និងពាក់ព័ន្ធនឹងផ្នែកសេវាអតិថិជន ភាគីអ្នកលក់អាចមានការចាំបាច់ដើម្បីបញ្ចេញព័ត៌មាន ឬផ្ទេរព័ត៌មានដែលអ្នកបានផ្ដល់ជូនមកខាងយើង ជូនទៅខាងស្ថាប័នដែលជាផ្នែកនៃក្រុមហ៊ុន SELLER Group។

## 6. តើអ្នកមានសិទ្ធិអ្វីខ្លះនៅពេលផ្ដល់ទិន្នន័យមកខាងយើងខ្ញុំ?

យើងសន្យារក្សាទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកជាការសម្ងាត់ និងធានាថា អ្នកអាចអនុវត្ត**សិទ្ធិរបស់អ្នកបាន**។ អ្នកអាចអនុញ្ញាតសិទ្ធិរបស់អ្នក**ដោយឥតគិតថ្លៃ** ដោយសរសេរមកកាន់អ៊ីមែលតែមួយគត់របស់យើងគឺ dataprotection@zara.com ដោយគ្រាន់តែជូនដំណឹងយើងអំពីមូលហេតុនៃការស្នើសុំ និងសិទ្ធិដែលអ្នកចង់អនុវត្ត។ ប្រសិនបើយើងចាត់ទុកថាសំណើនេះមានការចាំបាច់ដើម្បីអាចកំណត់អត្តសញ្ញាណរបស់អ្នកបាន យើងអាចធ្វើការស្នើសុំអ្នកឱ្យផ្ដល់សំណៅថតចម្លងនៃឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នក។

បន្ថែមលើនេះ យើងអាចផ្ដល់ជូនដល់អ្នកនូវលទ្ធភាពក្នុងការអនុវត្តសិទ្ធិរបស់អ្នក និងការកំណត់ចំណង់ចំណូលចិត្តឯកជនភាពរបស់អ្នក នៅពេលប្រើប្រាស់សេវាកម្មខ្លះរបស់យើង ឬតាមរយៈបណ្ដាញជាក់លាក់ដែលមានផ្ដល់ជូននៅក្នុងប្រព័ន្ធវេទិការបស់យើង។ ជាពិសេស ពុំគិតពីគោលបំណង ឬមូលដ្ឋានផ្លូវច្បាប់ដែលយើងប្រើដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់អ្នក អ្នកមានសិទ្ធិដូចខាងក្រោមៈ

- ធ្វើការស្នើសុំការចូលទៅមើលទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ដែលយើងរក្សាទុក។ យើងសូមរំឭកអ្នកថា នៅត្រង់ចំណុចណាដែលអ្នកជាអ្នកប្រើប្រាស់ដែលបានចុះឈ្មោះរបស់ប្រព័ន្ធវេទិកាមនេះ អ្នកក៏អាចមើលព័ត៌មាននេះបាននៅក្នុងផ្នែកដែលពាក់ព័ន្ធនឹងគណនីអនឡាញរបស់អ្នកផងដែរ។

- ដើម្បីស្នើសុំឱ្យយើងធ្វើការ**កែតម្រូវ**ទិន្នន័យដែលយើងរក្សាទុក។ សូមចងចាំទុកក្នុងចិត្តថា ប្រសិនបើអ្នកជាអ្នកប្រើប្រាស់ដែលបានចុះឈ្មោះលើវេទិកាមនេះ អ្នកក៏អាចចូលទៅមើលផ្នែកទិន្នន័យផ្ទាល់ខ្លួនដែលពាក់ព័ន្ធនៃគណនីអនឡាញរបស់អ្នក ដើម្បីធ្វើការផ្លាស់ប្ដូរ ឬអាប់ដេតទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។ ក្នុងករណីណាមួយ សូមគិតពិចារណាថា ចំពោះការផ្ដល់ទិន្នន័យផ្ទាល់ខ្លួនរបស់យើងដោយសកម្មមកខាងយើងខ្ញុំតាមរយៈនីតិវិធីណាមួយ អ្នកធានាថា ទិន្ន័យទាំងនោះ **ត្រឹមត្រូវនិងច្បាស់លាស់** ហើយអ្នកសន្យាថានឹងជូនដំណឹងដល់យើងអំពីការផ្លាស់ប្ដូរ ឬការកែតម្រូវណាមួយចំពោះទិន្នន័យរបស់អ្នក។ អ្នកនឹងមានទំនួលខុសត្រូវចំពោះការខាតបង់ និងការខូចខាតដែលបង្កទៅលើប្រព័ន្ធវេទិកាមនេះ ឬទៅលើបុគ្គលដែលទទួលខុសត្រូវចំពោះប្រព័ន្ធវេទិកាមនេះ ឬទៅកាន់ភាគីទីបី តាមការរាយការណ៍ព័ត៌មានខុស មិនត្រឹមត្រូវ ឬមិនពេញលេញនៅក្នុងទម្រង់បែបបទនៃការចុះឈ្មោះ។ សូមចងចាំថា ក្នុងលក្ខណៈជាវិធានទូទៅ អ្នកត្រូវផ្ដល់ជូនយើងត្រឹមតែទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកប៉ុណ្ណោះ មិនមែនទិន្នន័យរបស់ភាគីទីបី ក្រៅពីវិសាលភាពដែលអនុញ្ញាតដោយគោលនយោបាយនេះ។

- ដើម្បីធ្វើការស្នើសុំឱ្យយើងលុបចោលនូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកក្នុងវិសាលភាពដែលទិន្នន័យទាំងនោះពុំមានការចាំបាច់សម្រាប់គោលបំណងដែលយើងត្រូវការដើម្បីវិភាគទិន្នន័យទាំងនោះ

ទៀត ដូចដែលយើងបានពន្យល់ពីខាងលើ ឬនៅពេលដែលយើងលែងទទួលបានការអនុញ្ញាតស្របច្បាប់ដើម្បីប្រមូលនិងវិភាគទិន្នន័យទាំងនោះទៀត។

- ដើម្បីស្នើសុំឱ្យយើង**លុបចោល ឬដាក់កំហិតលើការប្រមូលនិងវិភាគទិន្នន័យ**ផ្ទាល់ខ្លួនរបស់អ្នកដែលមានន័យថា នៅក្នុងករណីជាក់លាក់ខ្លះ អ្នកអាចស្នើសុំឱ្យយើងពន្យារការប្រមូលនិងវិភាគទិន្នន័យជាបណ្តោះអាសន្ន ឬឱ្យយើងរក្សាទុកទិន្នន័យទាំងនោះឱ្យយូរជាងពេលដែលចាំបាច់។

ប្រសិនបើអ្នកបានផ្តល់**ការយល់ព្រម**ដល់ក្រុមហ៊ុន ITX MERKEN ដើម្បីធ្វើការប្រមូលនិងវិភាគទិន្នន័យរបស់អ្នកសម្រាប់គោលបំណងណាមួយ អ្នក**ក៏មានសិទ្ធិក្នុងការដកការយល់ព្រមនោះវិញបានគ្រប់ពេលវេលាផងដែរ**។ កាលៈទេសៈមួយចំនួនដែលអ្នកអាចដកការយល់ព្រមរបស់អ្នកវិញ មានរៀបរាប់លម្អិតនៅក្នុងផ្នែកទី 2 ដែលយើងពន្យល់អំពីគោលបំណងដែលយើងប្រមូលនិងវិភាគទិន្នន័យរបស់អ្នក។

ប្រសិនបើអ្នកមិនចង់ឱ្យយើងផ្ញើព័ត៌មានទៅកាន់ភាគីទីបីដើម្បីឱ្យគេបង្ហាញពាណិជ្ជកម្មដល់អ្នក អ្នកអាចធ្វើបែបនោះបានតាមរយៈមធ្យោបាយមួយចំនួនដូចជា ការផ្លាស់ប្តូរចំណង់ចំណូលចិត្តរបស់អ្នកនៅលើឧបករណ៍របស់អ្នក កម្មវិធីប្រាវស័រ និង/ឬការកំណត់ខូឃី ការពិនិត្យមើលគោលនយោបាយស្តីពីឯកជនភាព និងការកំណត់ទំព័របណ្តាញសង្គមដែលអ្នកមានប្រូហ្វាល់ ឬផ្ញើអ៊ីមែលមកយើងទៅកាន់អាសយដ្ឋានអ៊ីមែលដែលបានបញ្ជាក់ ដើម្បីជូនដល់យើងអំពីការស្នើសុំរបស់អ្នក។

នៅពេលដែលយើងទទួលបានការអនុញ្ញាតស្របច្បាប់ដើម្បីធ្វើការប្រមូលនិងវិភាគទិន្នន័យរបស់អ្នកដោយសារមាន**ការយល់ព្រម**ពីអ្នក ឬសម្រាប់គោលបំណងនៃកិច្ចសន្យា ដូចមានពន្យល់ក្នុងផ្នែកទី 3 អ្នកក៏នឹងមានសិទ្ធិក្នុងការស្នើសុំ**ការផ្ទេរទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក**។ នេះមានន័យថា អ្នកមានសិទ្ធិក្នុងការទទួលបានទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ដែលអ្នកបានផ្តល់ជូនដល់យើងតាមការណែនាំ ក្នុងទម្រង់ដែលបានប្រើប្រាស់ជាទូទៅ និងអានដាច់ដោយម៉ាស៊ីន ដើម្បីអាចផ្ទេរទិន្នន័យទាំងនោះទៅកាន់អង្គភាពមួយទៀតដោយផ្ទាល់ ដោយគ្មានការជំទាស់ពីខាងយើងឡើយ។

បន្ថែមលើនេះ នៅត្រង់ចំណុចណាដែលការប្រមូលនិងការវិភាគទិន្នន័យផ្អែកលើ**ផលប្រយោជន៍ស្របច្បាប់**របស់យើង អ្នកក៏នឹងមានសិទ្ធិក្នុងការ**បដិសេធ**លើការប្រមូលនិងវិភាគទិន្នន័យនោះដែរ។

ចុងក្រោយ យើងជូនដំណឹងដល់អ្នកថា អ្នកមានសិទ្ធិក្នុងការដាក់បណ្តឹងទាមទារនៅចំពោះមុខ**អាជ្ញាធរនិយ័តកម្ម**ការការពារទិន្នន័យដែលមានទំនួលខុសត្រូវ ជាពិសេស នៅចំពោះមុខ៖

- អាជ្ញាធរការពារទិន្នន័យហូឡង់ (Autoriteit Persoonsgegevens) https://autoriteitpersoonsgegevens.nl/nl
- អាជ្ញាធររបស់ប្រទេសដែលក្រុមហ៊ុនលក់រាយរបស់យើងមានទីតាំងនៅ។

## 7. នៅពេលអ្នកផ្តល់ទិន្នន័យរបស់ភាគីទីបីដល់យើងខ្ញុំ ឬប្រសិនបើភាគីទីបីបានផ្តល់ទិន្នន័យរបស់ដល់ខាងយើងខ្ញុំ តើនឹងមានរឿងអ្វីកើតឡើង?

យើងផ្តល់ជូនមុខងារ និងសេវាកម្មនានាដែលតម្រូវឱ្យយើងប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់ភាគីទីបីដែលអ្នក ក្នុងនាមជាអ្នកប្រើប្រាស់ឬក្នុងនាមអតិថិជន ត្រូវតែផ្តល់ជូន ដូចជាករណីនៃការបើកដំណើរការនិងការផ្ញើប័ណ្ណរង្វាន់ ការគ្រប់គ្រងកម្មវិធីសម្រាប់សក្ខីបត្ររង្វាន់ (នៅត្រង់ចំណុចដែលមានផ្តល់ជូនមុខងារទាំងនេះ) ឬនៅពេលអ្នកអនុញ្ញាតឱ្យភាគីទីបីប្រមូលការបញ្ជាទិញនៅក្នុងហាងរបស់យើង ឬស្ថាប័នរបស់ដៃគូ។ ប្រសិនបើអ្នកផ្តល់ទិន្នន័យផ្ទាល់ខ្លួនរបស់ភាគីទីបីមកខាងយើង ឬប្រសិនបើមានការចាំបាច់ដែលតម្រូវឱ្យយើងស្នើសុំទិន្នន័យទាំងនោះសម្រាប់ភាគីទីបី ដើម្បីប្រមូលការបញ្ជាទិញក្នុងឈ្មោះរបស់អ្នក អ្នកត្រូវបញ្ជាក់ថា

អ្នកបានជូនដំណឹងទៅពួកគេអំពីគោលបំណង និងលក្ខណៈដែលយើងត្រូវការប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេ។

ប្រសិនបើភាគីទីបីបានផ្តល់ទិន្នន័យរបស់អ្នកមកខាងយើង ឬអ្នកបានផ្តល់ជូនពួកគេដោយខ្លួនឯងដោយសារមុខងារណាមួយ ឬសេវាកម្មដែលបានស្នើដោយអ្នកប្រើប្រាស់ណាម្នាក់របស់យើង នោះយើងនឹងប្រើប្រាស់ទិន្នន័យទាំងនោះដើម្បីគ្រប់គ្រងមុខងារ ឬសេវាកម្មដែលបានលើកឡើងក្នុងករណីនីមួយៗស្ថិតក្រោមដែនកំណត់នៃគោលបំណងដែលមានចែងនៅក្នុងគោលនយោបាយនេះ តំណភ្ជាប់ទៅកាន់ផ្នែកនេះ តែងមានដាក់បញ្ចូលនៅក្នុងការប្រាស្រ័យទាក់ទងគ្នារបស់យើងជានិច្ច។

## 8. ការផ្លាស់ប្តូរទៅលើគោលការណ៍នេះ

យើងអាចធ្វើការកែប្រែព័ត៌មានដែលមាននៅក្នុងគោលការណ៍នេះ នៅពេលដែលយើងចាត់ទុកសមស្រប។ ប្រសិនបើយើងធ្វើការកែប្រែមែន យើងនឹងជូនដំណឹងដល់អ្នកតាមនីតិវិធីផ្សេងៗតាមរយៈប្រព័ន្ធផ្គូផ្គងនេះ (ឧទាហរណ៍ តាមរយៈផ្ទាំងបេន័រ ការជូនដំណឹងផុសឡើង ឬការជំរុញការជូនដំណឹង) ឬយើងអាចនឹងផ្ញើការជូនដំណឹងមួយទៅកាន់អាសយដ្ឋានអ៊ីមែលរបស់អ្នក នៅពេលការប្តូរដែលបានលើកឡើងនោះពាក់ព័ន្ធនឹងសិទ្ធិឯកជនភាពរបស់អ្នក ដើម្បីឱ្យអ្នកអាចត្រួតពិនិត្យការផ្លាស់ប្តូរនោះ វាយតម្លៃ និងអាចធ្វើការបដិសេធ ឬឈប់ចុះឈ្មោះចេញពីសេវាកម្ម ឬមុខងារនោះបាន ទៅតាមករណីជាក់ស្តែង។ ទោះក្នុងករណីណាក៏ដោយ យើងសូមណែនាំឱ្យអ្នកធ្វើការពិនិត្យគោលការណ៍នេះឡើងវិញពីពេលមួយទៅពេលមួយ ក្នុងករណីមានការផ្លាស់ប្តូរតិចតួចត្រូវបានធ្វើឡើង ឬយើងធ្វើការកែលម្អការទំនាក់ទំនង ដោយយកឱកាសដែលអ្នកតែងចាត់ទុកវាជាចំណុចទទួលព័ត៌មានអចិន្ត្រៃយ៍នៅលើវេបសាយ ឬអេបកម្មវិធីរបស់យើង។

## 9. ព័ត៌មានអំពីខូឃី

យើងប្រើប្រាស់ខូឃី និងឧបករណ៍ស្រដៀងគ្នានេះ ដើម្បីសម្រួលដល់ការស្វែងរករបស់អ្នកនៅលើប្រព័ន្ធផ្គូផ្គងនេះ ដើម្បីដឹងអំពីរបៀបដែលអ្នកទាក់ទងជាមួយយើង ហើយក្នុងករណីជាក់លាក់ខ្លះ ដើម្បីអាចបង្ហោះពាណិជ្ជកម្មដល់អ្នកស្របតាមទម្លាប់នៃការស្វែងរករបស់អ្នក។ សូមបន្តអានដើម្បីឱ្យបានលម្អិតស៊ីជម្រៅជាងនេះអំពីខូឃី និងឧបករណ៍ស្រដៀងគ្នាដែលយើងប្រើប្រាស់អំពីគោលបំណង របៀបគ្រប់គ្រងចំណង់ចំណូលចិត្តរបស់អ្នក ក៏ដូចជាព័ត៌មានចាប់អារម្មណ៍ដទៃផ្សេងទៀតផងដែរ។

# គោលការណ៍ស្ដីពីខូឃី

## មុនពេលអ្នកចាប់ផ្ដើម...

នៅក្នុងគោលការណ៍ស្ដីពីខូឃីនេះ អ្នកនឹងឃើញព័ត៌មានអំពីរបៀបដែលយើងប្រើប្រាស់ខូឃី និងឧបករណ៍ស្រដៀងគ្នាដែលបានដំឡើងនៅលើម៉ាស៊ីនគិតប្រាក់របស់អតិថិជន ឬអ្នកប្រើប្រាស់របស់យើង។ ការប្រើប្រាស់ខូឃីពេលខ្លះ អាចមានពាក់ព័ន្ធនឹងការប្រមូលនិងវិភាគទិន្នន័យ ហេតុនេះ យើងសូមណែនាំឱ្យអ្នកអានគោលការណ៍សិទ្ធិឯកជនភាពរបស់យើង ដែលមាននៅលើប្រព័ន្ធផ្លែតហ្វមរបស់យើង ប្រសិនបើអ្នកចង់បានព័ត៌មានអំពីរបៀបដែលយើងប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អតិថិជន ឬអ្នកប្រើប្រាស់របស់យើង របៀបអនុវត្តសិទ្ធិរបស់អ្នក ឬបច្ចេកវិទ្យាដែលយើងប្រើដើម្បីយោងទៅកាន់ប្រព័ន្ធផ្លែតហ្វមរបស់យើង (វេបសាយ អែបកម្មវិធី ឬហាងលក់ទំនិញ)។

## 1. ព័ត៌មានអំពីខូឃី

### 1. តើខូឃីគឺជាអ្វី?

ខូឃីគឺជាហ្វាល់អត្ថបទតូចមួយដែលវេបសាយ អែបកម្មវិធី ឬប្រព័ន្ធផ្លែតហ្វមដទៃទៀតរក្សាទុកនៅលើកុំព្យូទ័រ ថេមផ្លឹត ទូរសព្ទស្មាតហ្វូន ឬឧបករណ៍ស្រដៀងគ្នានោះ ដែលមានផ្ទុកព័ត៌មានអំពីការស្វែងរក និងការប្រើប្រាស់របស់អ្នក ដូចជាស្លាកមួយដែលសម្គាល់ឧបករណ៍របស់អ្នកដែរ។ ឧទាហរណ៍ ខូឃីមានការចាំបាច់ដើម្បីសម្រួលដល់ការស្វែងរក និងការយល់ពីរបៀបដែលអ្នកប្រើប្រាស់ទាក់ទងជាមួយប្រព័ន្ធផ្លែតហ្វម ដើម្បីឱ្យអាចធ្វើការកែលម្អបាន។ ខូឃីក៏មានប្រយោជន៍ក្នុងការផ្ដល់ការផ្សាយពាណិជ្ជកម្មស្របតាមចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ ក៏ដូចជាគោលបំណងផ្សេងទៀតដែលមានចែងលម្អិតខាងក្រោមនេះផងដែរ។ ខូឃីពុំធ្វើឱ្យខូចកុំព្យូទ័រ ឬឧបករណ៍របស់អ្នកឡើយ។

តាមរយៈពាក្យ “ខូឃី” នេះ យើងក៏ចង់សំដៅលើបច្ចេកវិទ្យាផ្សេងស្រដៀងគ្នាដែលបានប្រើដើម្បីដំឡើង និង/ឬប្រមូលព័ត៌មាននៅលើឬពីឧបករណ៍របស់អ្នកផងដែរ ដូចជា ខូឃីហ្វ្លាស់ វេបប៊ីខុន ឬពពួកមេរោគ ភិចសែល HTML5 (មូលដ្ឋានរក្សាទុកផ្ទៃក្នុង) និងបច្ចេកវិទ្យា SDK សម្រាប់អែបកម្មវិធីទាំងនោះផង។ ពាក្យខូឃីក៏មានន័យសំដៅលើការប្រើប្រាស់ស្នាមក្រយៅម្រាមដៃ និយាយមួយបែបទៀត គឺសំដៅលើបច្ចេកវិទ្យាដែលប្រើដើម្បីរួមបញ្ចូលព័ត៌មានដែលជួយយើងក្នុងការកំណត់អត្តសញ្ញាណឧបករណ៍របស់យើង។ បច្ចេកវិទ្យាទាំងនេះពេលខ្លះក៏ដំណើរការជាមួយនឹងខូឃីដែរ ដើម្បីប្រមូលនិងរក្សាទុកព័ត៌មាន ដើម្បីផ្ដល់ជូនអ្នកនូវមុខងារជាក់លាក់ ឬសេវាកម្មនៅលើប្រព័ន្ធផ្លែតហ្វមរបស់យើង ឬដើម្បីបង្ហាញពាណិជ្ជកម្មរបស់ភាគីទីបីស្របតាមការស្វែងរករបស់អ្នក។

ការពន្យល់នេះ គឺជាទិដ្ឋភាពទូទៅនៃអត្ថន័យរបស់ខូឃី ហើយសម្រាប់គោលបំណងនៃការផ្ដល់ព័ត៌មានតែប៉ុណ្ណោះ។ ខូឃីជាក់លាក់ដែលយើងប្រើ មានរៀបរាប់លម្អិតនៅក្នុងផ្ទាំងកំណត់ខូឃីនៅលើប្រព័ន្ធផ្លែតហ្វមរបស់យើង។

2. **តើខូឃីមានប៉ុន្មានប្រភេទ?**

សូមពិនិត្យមើលផ្នែកនេះ ដែលផ្តល់ទិដ្ឋភាពទូទៅអំពីប្រភេទនៃខូឃីដែលអាចត្រូវបានប្រើប្រាស់នៅក្នុងមជ្ឈដ្ឋានអនឡាញ។

ខូឃីអាចចាត់ថ្នាក់ដូចខាងក្រោម អាស្រ័យលើម្ចាស់គ្រប់គ្រង៖

a. ខូឃីរបស់ភាគីទីមួយ៖ ត្រូវបានផ្ញើទៅកាន់កុំព្យូទ័រ ឬឧបករណ៍របស់អ្នកប្រើប្រាស់ចេញពីកុំព្យូទ័រ ឬដូម៉េនមួយដែលគ្រប់គ្រងដោយអ្នកកែប្រែ ហើយផ្តល់ជាប្រព័ន្ធផ្លេតហ្វម ឬសេវាកម្មតាមការស្នើសុំដោយអ្នកប្រើប្រាស់។

b. ខូឃីរបស់ភាគីទីបី៖ ត្រូវបានផ្ញើទៅកាន់កុំព្យូទ័រ ឬឧបករណ៍របស់អ្នកប្រើប្រាស់ចេញពីកុំព្យូទ័រ ឬដូម៉េនដែលមិនគ្រប់គ្រងដោយអ្នកកែប្រែ តែត្រូវបានគ្រប់គ្រងដោយអង្គភាពមួយផ្សេងទៀតដែលប្រមូលនិងវិភាគទិន្នន័យដែលប្រមូលបានពីខូឃីនោះ។

ខូឃីអាចចាត់ថ្នាក់ដូចខាងក្រោម អាស្រ័យលើគោលបំណង៖

a. ខូឃីដែលមានការចាំបាច់បំផុត (បច្ចេកទេស)៖ ខូឃីដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ស្វែងរកលើវេបសាយ ផ្លេតហ្វម ឬអែបកម្មវិធី និងប្រើប្រាស់ជម្រើស ឬសេវាកម្មផ្សេងៗនៅលើនោះ។ ឧទាហរណ៍ គ្រប់គ្រងចរាចរណ៍ កំណត់ទិន្នន័យ ឬវគ្គ ចូលទៅកាន់ផ្នែកឬខ្លឹមសារដែលរឹតបន្តឹងការចូលទៅមើល ចងចាំចំណុចតូចៗនៃការបញ្ជាទិញណាមួយ បំពេញដំណើរការនៃការបញ្ជាទិញ គ្រប់គ្រងការទូទាត់ គ្រប់គ្រងក្លែងបន្លំពាក់ព័ន្ធនឹងសន្តិសុខសេវាកម្ម ប្រើប្រាស់ធនធានសន្តិសុខក្នុងអំឡុងពេលស្វែងរក បំពេញពាក្យស្នើសុំដើម្បីចុះឈ្មោះ ឬចូលរួមក្នុងព្រឹត្តិការណ៍មួយ រក្សាទុកខ្លឹមសារសម្រាប់ការបង្ហោះវីដេអូ និងសំឡេង បើកដំណើរការខ្លឹមសារឌីណាមិច (ឧទាហរណ៍ ការទាញផ្ទុករូបជីវចលនៃអត្ថបទ ឬរូបភាព) និងចែករំលែកខ្លឹមសារនៅលើបណ្តាញព័ត៌មានសង្គម។ ដោយសារតែខូឃីនោះមានការចាំបាច់ខានមិនបាន ខូឃីបច្ចេកទេសត្រូវបានទាញយកដោយការកំណត់ នៅពេលត្រូវការពួកគេដើម្បីបង្ហាញផ្លេតហ្វម ឬផ្តល់សេវាកម្មដែលបានស្នើសុំដោយអ្នកប្រើប្រាស់។

b. ខូឃីមុខងារ ឬខូឃីកំណត់តម្រូវតាមចិត្ត៖ ខូឃីទាំងនេះ ត្រូវការជាចាំបាច់ដើម្បីចងចាំព័ត៌មាន ដើម្បីឱ្យអ្នកប្រើប្រាស់អាចទទួលបានសេវាកម្ម ឬប្រព័ន្ធផ្លេតហ្វមដែលមានលក្ខណៈពិសេសជាក់លាក់ ដែលអាចញែកបទពិសោធរបស់ពួកគេចេញពីបទពិសោធរបស់អ្នកប្រើប្រាស់ផ្សេងទៀត។ ឧទាហរណ៍ ភាសា ចំនួននៃលទ្ធផលដែលបានបង្ហាញនៅពេលអ្នកប្រើប្រាស់ដំណើរការស្វែងរក ការលេចចេញនូវខ្លឹមសារនៃសេវាកម្មផ្អែកលើប្រភេទកម្មវិធីប្រាវស័រដែលបានប្រើប្រាស់ ឬតំបន់ដែលចូលទៅប្រើសេវាកម្មនោះ។ល។ ការមិនទទួលយកខូឃីអាចបណ្តាលឱ្យដំណើរការវេបសាយដើរយឺត ឬអនុសាសន៍ដែលបានទទួលយកមិនសូវល្អ។

c. ខូឃីសម្រាប់ការវិភាគ៖ ខូឃីទាំងនេះ អាចបង្កើនចំនួនអ្នកប្រើប្រាស់ ផ្នែកដែលបានចូលទស្សនានៅលើផ្លេតហ្វម និងរបៀបដែលអ្នកប្រើប្រាស់ទាក់ទងជាមួយវា ដើម្បីអនុវត្តវិធានការស្ថិតិ និងការវិភាគលើការប្រើប្រាស់ ដើម្បីអនុវត្តការកែលម្អផ្អែកលើការវិភាគទិន្នន័យអំពីរបៀបដែលអ្នកប្រើប្រើប្រាស់ប្រើប្រព័ន្ធផ្លេតហ្វម ឬសេវាកម្មនេះ។

d. ខូឃីពាណិជ្ជកម្មទៅតាមអាកប្បកិរិយា៖ គឺជាខូឃីដែលរក្សាទុកព័ត៌មានអំពីអាកប្បកិរិយារបស់អ្នកប្រើប្រាស់ដែលទទួលបានពីអង្កេតជាបន្តបន្ទាប់នៃទម្លាប់ស្វែងរករបស់ពួកគេ ដែលអនុញ្ញាតឱ្យយើងបង្កើតលក្ខណៈជាក់លាក់មួយសម្រាប់បង្ហាញពាណិជ្ជកម្មដែលបានបង្កើតឡើងតាមទម្លាប់ទាំងនេះ។ ខូឃីទាំងនេះអនុញ្ញាតឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពបំផុតលើលំហនៃការផ្សាយពាណិជ្ជកម្ម ដែលអ្នកកែប្រែបានរួមបញ្ចូលដោយផ្ទាល់ ឬនៅក្នុងការសហការគ្នាជាមួយភាគីទីបី។

### 3. តើមានខូឃីអ្វីខ្លះដែលបានប្រើសម្រាប់គេហទំព័ររបស់យើង?

ខូឃីគឺជាផ្នែកដ៏សំខាន់មួយនៃរបៀបដែលប្រព័ន្ធផ្លេតហ្វមរបស់យើងមានដំណើរការ។ គោលបំណងសំខាន់បំផុតរបស់ខូឃីរបស់យើងគឺដើម្បីធ្វើឱ្យបទពិសោធនៃការស្វែងរករបស់អ្នកកាន់តែងាយស្រួល និងមានប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍ អាចប្រើខូឃីទាំងនោះដើម្បីចងចាំពីចំណង់ចំណូលចិត្តរបស់អ្នក (ភាសា ប្រទេស ។ល។) នៅពេលអ្នកស្វែងរក និងចូលមកមើលនៅពេលអនាគត។ យើងក៏ប្រើប្រាស់ខូឃីដើម្បីកែលម្អសេវាកម្មនិងប្រព័ន្ធផ្លេតហ្វមរបស់យើងជាបន្តបន្ទាប់ផងដែរ និងដើម្បីផ្តល់ជូននូវការផ្សាយពាណិជ្ជកម្មតាមចំណង់ចំណូលចិត្ត ស្របតាមទម្លាប់នៃការស្វែងរករបស់អ្នក។

ព័ត៌មានដែលបានប្រមូលពាក់ព័ន្ធនឹងខូឃី ក៏អនុញ្ញាតឱ្យយើងកែលម្អប្រព័ន្ធផ្លេតហ្វមរបស់យើង តាមរយៈការធ្វើការប៉ាន់ស្មានអំពីទិន្នន័យស្ថិត និងទម្រង់នៃការប្រើប្រាស់ (ចំនួននៃការទស្សនា ផ្នែកដែលទស្សនាច្រើនបំផុត ពេលវេលាចូលទស្សនា ។ល។) ទទួលបានការយល់ដឹងខាងស្ថិតិអំពីរបៀបដែលអ្នកប្រើប្រាស់ប្រាស្រ័យទាក់ទងជាមួយប្រព័ន្ធផ្លេតហ្វម ដើម្បីធ្វើការកែលម្អសេវាកម្មរបស់យើង និងដើម្បីជ្រើសយកផ្លេតហ្វមទៅតាមចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់អ្នក ពន្លឿនល្បឿននៃការស្វែងរក ។ល។

ពេលខ្លះ យើងអាចប្រើប្រាស់ខូឃីនេះដើម្បីទទួលបានព័ត៌មានដែលអនុញ្ញាតឱ្យយើងបង្ហាញពាណិជ្ជកម្មពីផ្លេតហ្វមរបស់យើង ប្រព័ន្ធផ្លេតហ្វមរបស់ភាគីទីបី ឬមធ្យោបាយផ្សេងទៀតណាមួយ ផ្អែកតាមការវិភាគពីទម្លាប់នៃការស្វែងរករបស់អ្នក (ផលិតផលដែលបានមើល ផ្នែកដែលបានអាន ។ល។)។

ក្នុងករណីណាក៏ដោយ ខូឃីដែលយើងប្រើ <u>មិនដែល</u> រក្សាទុកនូវព័ត៌មានរសើបដូចជា លេខកូដសម្ងាត់ ព័ត៌មានលម្អិតរបស់ប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ ។ល។

### 4. តើខ្ញុំអាចគ្រប់គ្រងការប្រើប្រាស់ខូឃីនៅលើគេហទំព័រនេះបានដោយរបៀបណា?

នៅក្នុងផ្ទាំងកំណត់ខូឃី ដែលអាចស្វែងរកបានគ្រប់ពេលនៅលើគេហទំព័ររបស់យើង អ្នកអាចស្វែងរកព័ត៌មានគ្រប់យ៉ាងអំពីខូឃីដែលបានប្រើប្រាស់ដោយគេហទំព័ររបស់យើង រួមជាមួយនឹងព័ត៌មានអំពីគោលបំណង រយៈពេល និងការគ្រប់គ្រង (ភាគីទីមួយ ឬភាគីទីបី) ខូឃីនីមួយៗ ដើម្បីឱ្យអ្នកអាចបើកដំណើរការ ឬបិទដំណើរការការប្រើប្រាស់ខូឃី ដែលមិនមានសារៈសំខាន់ខ្លាំងសម្រាប់មុខងារគេហទំព័រនេះ។

ជម្រើសផ្សេងទៀត ប្រសិនបើស្វែងរកតាមអ៊ីនធឺណិត អ្នកអាចបិទដំណើរការការប្រើប្រាស់ខូឃីនៅក្នុងកម្មវិធីប្រាវស័ររបស់អ្នកបាន។ ទាំងនេះគឺជារបៀបដែលអាចធ្វើបែបនេះបាននៅលើកម្មវិធីប្រាវស័រពេញនិយមមួយចំនួន៖

- Google Chrome
- Internet Explorer
- Mozilla Firefox
- Safari

អ្នកអាចបង្ការការប្រើប្រាស់ខូឃីបានគ្រប់ពេលទាំងអស់។

សូមចងចាំថា ទាំងការគ្រប់គ្រងផ្ទាំងកំណត់ខូឃី និងការជ្រើសរើសបដិសេធខូឃី គឺមានលក្ខណៈជាក់លាក់ទៅតាមកម្មវិធីប្រាវស័រនីមួយៗដែលអ្នកកំពុងប្រើប្រាស់។ ហេតុនេះ ប្រសិនបើអ្នកភ្ជាប់ខូឃីតាមរបៀបមួយនៅឧបករណ៍មួយ ហើយចង់ឱ្យជម្រើសរបស់អ្នកអនុវត្តដូចគ្នាចំពោះឧបករណ៍ផ្សេងទៀត អ្នកត្រូវបើកដំណើរការជម្រើសដូចគ្នានៅលើឧបករណ៍ផ្សេងទៀត។

បន្ថែមលើនេះ ពាក់ព័ន្ធខូឃីរបស់ភាគីទីបីដែលប្រើដើម្បីផ្តល់ការផ្សាយពាណិជ្ជកម្មផ្អែកលើផលប្រយោជន៍របស់អ្នក សូមកត់សម្គាល់ថា ភាគីទីបីអាចជាសមាជិកនៃកម្មវិធីស្វ័យនិយតកម្មដូចខាងក្រោម សម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្មមានលក្ខណៈជាអនឡាញ ដែលមានជម្រើសផ្តាច់មុខស្ម័គ្រចិត្តពាក់ព័ន្ធ៖

- គំនិតផ្តួចផ្តើមផ្សាយពាណិជ្ជកម្មតាមបណ្តាញ (NAI) - http://www.networkadvertising.org/choices/
- ក្រុមហ៊ុន Google Analytics - https://tools.google.com/dlpage/gaoptout

### 5. តើនរណាប្រើព័ត៌មានដែលបានរក្សាទុកនៅលើយុកឃី?

ព័ត៌មានដែលរក្សាទុកនៅក្នុងខូឃីផ្លេតហ្វមរបស់យើង គឺត្រូវបានប្រើតែដោយខាងយើងខ្ញុំប៉ុណ្ណោះ លើកលែងតែព័ត៌មានដែលមានចែងនៅក្នុងផ្នែកទី 2 ជា “ខូឃីភាគីទីបី” ដែលត្រូវបានប្រើប្រាស់ និងគ្រប់គ្រងដោយអង្គភាពទីបី ដើម្បីផ្តល់ជូនយើងនូវសេវាកម្មដែលមានគោលបំណងក្នុងការពង្រឹងសេវាកម្មរបស់យើង និងអ្នកប្រើប្រាស់បទពិសោធ នៅពេលស្វែងរកនៅលើប្រព័ន្ធផ្លេតហ្វមរបស់យើង។ ព័ត៌មានបន្ថែមអំពីផ្ទាំងកំណត់ខូឃីមានផ្តល់ជូនគ្រប់ពេលវេលានៅលើប្រព័ន្ធផ្លេតហ្វមរបស់យើង។

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីរបៀបដែលយើងប្រមូលនិងវិភាគទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងការសហការជាមួយភាគីទីបី និងពាក់ព័ន្ធនឹងទិន្នន័យស្ថិតក្រោមការផ្ទេរទិន្នន័យជាអន្តរជាតិ សូមអានគោលការណ៍សិទ្ធិឯកជនភាពរបស់យើងដែលមាននៅលើប្រព័ន្ធផ្លេតហ្វមរបស់យើង ហើយការកំណត់គោលការណ៍សិទ្ធិឯកជនភាព/គោលការណ៍របស់ក្រុមហ៊ុនសហការជាភាគីទីបីទាំងនេះ ដែលអាចស្វែងរកបាននៅលើប្រព័ន្ធផ្លេតហ្វមរបស់យើង។